ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Feb-2013, 13:00
CMS/CFO: Sann Rada

សម្ងាត់បំផុត/Strictly Confidential

គោរពជូន: ចៅក្រម យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ
ចៅក្រម Mark Harmon សហចៅក្រមស៊ើបអង្កេតអន្តរជាតិ
ការិយាល័យសហចៅក្រមស៊ើបអង្កេត

**សម្ងាត់ ប្ដូរទៅជាសាធារណៈ**

Isaac Endeley
ប្រធានអង្គភាពគាំពារការការពារក្ដី
ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣

**កម្មវត្ថុ: សំណើសុំការបញ្ជាក់**

លោកចៅក្រមជាទីគោរព

1. ខ្ញុំសរសេរលិខិតនេះសុំដំបូន្មាន និងការណែនាំពីលោកចៅក្រមទាក់ទងនឹងស្ថានភាពរបស់សហមេធាវីការពារដែលត្រូវបានចាត់តាំងដើម្បីតំណាងឱ្យជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ ។

2. ដូចដែលលោកចៅក្រមពិតជាបាននឹកឃើញហើយថានៅថ្ងៃទី៦ ខែមិនា ឆ្នាំ២០១២ អតីតសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ បានបង្គាប់អង្គភាពគាំពារការការពារក្ដី(“DSS”) ឱ្យចាត់តាំងមេធាវីការពារដើម្បីតំណាងឱ្យជនសង្ស័យនៅក្នុងសំណុំរឿង០០៣ និង០០៤ អនុលោមតាមវិធាន១១(២)(ង)(ច)(ឆ)(ជ)និង(ឈ)។ ក្នុងការប្រតិបត្តិតាមការបង្គាប់នេះ និងដើម្បីគោរពសិទ្ធិរបស់ជនសង្ស័យក្រោមវិធាន២១ អង្គភាពគាំពារការការពារក្ដីបានធ្វើបេសកម្មទៅជួបជនសង្ស័យនៅថ្ងៃទី១៤ ដល់ថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១២ និងថ្ងៃទី២៥ ដល់ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៣ និងថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២។ ដោយផ្អែកលើសំណើដែលស្នើឡើងដោយជនសង្ស័យពីរនាក់ក្នុងចំណោមជនសង្ស័យប្រាំនាក់ក្នុងអំឡុងពេលនៃការជួបទាំងនេះ ឬភ្លាមៗក្រោយការជួប និងដោយសំអាងលើការអះអាងរបស់ពួកគេ

អំពីភាពក្រីក្រ អង្គភាពគាំពារការការពារក្តីបានចាត់តាំងសហមេធាវីការពារក្តី និងបុគ្គលិកជំនួយការ ដើម្បីតំណាងឱ្យពួកគេនៅក្រោមគ្រោងការជំនួយការច្បាប់ ។

3. នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២ ខ្ញុំបានសរសេរលិខិតមួយច្បាប់ទៅការិយាល័យរបស់លោកចៅក្រម ដោយបានជូនដំណឹងដល់លោកចៅក្រមថា ខ្ញុំបានចាត់តាំងជាផ្លូវការលោក ម៉ុ លុជ្ស ជាសហមេធាវីកម្ពុជាឱ្យ តា អាន ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៤។ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១២ ខ្ញុំក៏បានសរសេរលិខិតជូនដំណឹងដល់លោកចៅក្រមអំពីការតាំងតាំងលោក Göran Sluiter ជាសហមេធាវីបរទេសឱ្យ តា អាន ។ ស្រដៀងគ្នានេះដែរ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ ខ្ញុំបានជូនដំណឹងដល់លោកចៅក្រមថាខ្ញុំបានចាត់តាំងលោក អាង ឧត្តម ជាសហមេធាវីកម្ពុជា និងលោក Michael G. Karnavas ជាសហមេធាវីបរទេសឱ្យលោក មាស មុត ជាសង្ស័យម្នាក់ក្នុងសំណុំរឿង០០៣ ។ បន្ថែមពីលើនេះ អង្គភាពគាំពារការការពារក្តីនាពេលថ្មីៗនេះកំពុងតែពិចារណាលើសំណើសុំការចាត់តាំងមេធាវីការពាររបស់ជនសង្ស័យទីបីផងដែរ ។

4. មកទល់ពេលនេះ ខ្ញុំមិនទាន់ទទួលបានការឆ្លើយតប ឬការទទួលស្គាល់ជាផ្លូវការពីការិយាល័យរបស់លោកពាក់ព័ន្ធនឹងការចាត់តាំងទាំងនេះឡើយ។ ដូច្នេះខ្ញុំនៅតែមិនច្បាស់ថា តើការិយាល័យរបស់លោកទទួលស្គាល់ ឬច្រានចោលមេធាវីដែលបានចាត់តាំងក្រោមគ្រោងការជំនួយផ្នែកច្បាប់ដើម្បីតំណាងឱ្យជនសង្ស័យខាងលើនេះដែរ ឬយ៉ាងណា។ ខ្ញុំក៏បានទទួលដំណឹងផងដែរថា សហមេធាវីដែលត្រូវបានចាត់តាំងរួចហើយនេះ មិនត្រូវបានអនុញ្ញាតឱ្យចូលមើលសំណុំរឿងកូនក្តីរបស់ពួកគេឡើយ។ អាស្រ័យហេតុនេះ ពួកគេមិនអាចតំណាងឱ្យកូនក្តីរបស់ពួកគេឱ្យបានគ្រប់គ្រាន់ឡើយ ហើយករណីនេះបង្កឱ្យមានក្តីបារម្ភយ៉ាងធ្ងន់ធ្ងរអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនសង្ស័យ។ មិនតែប៉ុណ្ណោះបញ្ហានេះក៏ធ្វើឱ្យអង្គភាពគាំពារការការពារក្តី មានការលំបាកក្នុងការចំណាយថវិកាដែលកំពុងខ្វះខាតរួចហើយនេះក្រោយគ្រោងការជំនួយផ្នែកច្បាប់ទៅលើមេធាវីដែលមិនអាចបំពេញកិច្ចការរបស់ពួកគេឱ្យបានពេញលេញ។

5. អាស្រ័យលើមូលហេតុដូចដែលបានរៀបរាប់ពីខាងលើ ហើយជាពិសេសដោយសារតែស្ថានភាពហិរញ្ញវត្ថុយ៉ាប់យឺនដែល អវតក កំពុងប្រឈមនៅពេលនេះ ខ្ញុំអរគុណលោកចៅក្រម ប្រសិនបើខ្ញុំបានទទួលការបញ្ជាក់ពីការិយាល័យរបស់លោកឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ ម្យ៉ាងវិញទៀត ប្រសិនបើលោកចៅក្រមមានបំណងមិនទទួលស្គាល់មេធាវីដែលបានចាត់តាំងទាំងនេះ តាមសេចក្តីណែនាំចុះថ្ងៃទី៦ ខែមិនា ឆ្នាំ២០១២ ឬប្រសិនបើលោកចៅក្រមជឿជាក់ថា ជនសង្ស័យក្នុងសំណុំរឿង០០៣ និង ០០៤ មិនទាន់មានសិទ្ធិទទួលបានមេធាវីទេនោះ សូមលោកចៅក្រមជូនដំណឹងមកខ្ញុំ ។ ម្យ៉ាងវិញទៀត

ប្រសិនបើលោកចៅក្រមសម្រេចថា មេធាវីត្រូវបានចាត់តាំងត្រឹមត្រូវតាមសេចក្តីណែនាំចុះថ្ងៃទី៦ ខែមិនា ឆ្នាំ២០១២ រួចហើយនោះ ខ្ញុំសូមឲ្យលោកទទួលស្គាល់ ហើយអនុញ្ញាតឲ្យពួកគេអាចចូលមើលសំណុំរឿងឲ្យបានឆាប់ តាមដែលអាចធ្វើទៅបានដើម្បីការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនសង្ស័យ។

Translation

ដោយក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

Isaac Endeley

ប្រធានអង្គភាពគាំពារការពារក្តី

ចម្លងជូន: លោក ក្រាន់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី

លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល/អ្នកសម្របសម្រួល UNAKRT

លោក Rajeev Kuma មន្ត្រីគ្រប់គ្រងកម្មវិធីជាន់ខ្ពស់

I.E. (3)